Fiscal Year
**2025**
**Proposed Budget**

CITY OF LONG BEACH

# សេចក្តីសង្ខេបអំពីថវិកា សហគមន៍











# ងាកមើលទិដ្ឋភាពរួមឆ្នាំ ២០២៤

ថយចុះចំនួនអ្នកដែលរស់នៅក្នុងស្ថានភាពអនាថា ដោយថយ ២,១ ភាគរយ នៅក្នុងការរាប់ជនអនាថា។ នេះជាការថយចុះចំនួនជនអនាថា ជាលើកដំបូង តាំងពីឆ្នាំ ២០១៧។

បានឯកភាពឲ្យសង់លំនៅឋាន ៣,០៣៩ ខ្នង និងចេញលិខិតអនុញ្ញាតឲ្យសាងសង់ ១,០១៣ ខ្នង ដោយរួមទាំងផ្ទះសង់បន្ថែម ADUs ចំនួន ៦៧៣ ខ្នង និងក្នុងឆ្នាំនេះផ្ទះ ៩៣៩ ខ្នងបានសង់រួចរាល់។

បានដាក់ឲ្យដំណើរការមជ្ឈមណ្ឌលសេវាសាធារណៈទីពីរ ដើម្បីផ្តល់សេវាជនអនាថា ដោយផ្ទាល់ដល់សហគមន៍របស់យើង ដែលសរុបមាន ១៦ ទីតាំង ក្នុងមួយសប្តាហ៍ នៅទូទាំងក្រុង។

នាយកដ្ឋានប៉ូលិសក្រុងឡុងប៊ិច បានបង្កើតក្រុមការងាររើស និងថែរក្សាបុគ្គលិក និងបើកឲ្យដំណើរការគម្រោងថ្មីៗ ដើម្បីរក្សាបុគ្គលិកដែលមានតម្លៃ និងរើសបុគ្គលិកថ្មី តាមរយៈកម្មវិធីរើស និងរក្សាបុគ្គលិក ដោយប្រើគ្រឿងលើកទឹកចិត្ត ដោយផ្តោតគោលដៅលើការរើសមន្ត្រីប៉ូលិសឲ្យបាន ១០០ នាក់ថ្មី ដើម្បីចេញល្បាត នៅក្នុងឆ្នាំ ២០២៤។

នាយកដ្ឋានអគ្គិភ័យ បានបង្កើតបណ្ឌិតសភារើសបុគ្គលិកពន្លត់អគ្គិភ័យ ជាប្រវត្តិសាស្រ្តនៃនាយកដ្ឋាននេះ។

បានអនុម័តដោយជោគជ័យនូវកិច្ចព្រមព្រៀងការងារ ដោយមានក្រុមការងារមិនពាក់ព័ន្ធនឹងសុវត្ថិភាពសាធារណៈចំនួនប្រាំបួនក្រុម។

បានអនុវត្តដោយពេញលេញផ្នែកបង្កើនទេពកោសលក្នុងផ្នែកធនធានមនុស្ស ដែលមានគោលដៅក្នុងការកែលម្អដំណើរការជ្រើសរើសបុគ្គលិក សម្រាប់តំណែងសេវាដែលមិនកំណត់។

ទូតឧទ្យានបានផ្តល់ការយកចិត្តទុកដាក់ក្នុងការថែទាំនិងជួសជុលបន្ថែម និងបិទបន្ទប់ទឹកសម្រាប់ពេលយប់ ដែលប្រការនេះធ្វើឲ្យសហគមន៍មានសុវត្ថិភាពជាងមុន និងការគោរពដល់គ្រឿងបរិក្ខារសំខាន់ៗនៃឧទ្យានទាំងនេះ។

កម្មវិធីជួយអាជីវកម្ម BizCare បានជួយអាជីវកម្ម ១,០១៨ អាជីវកម្ម តាមរយៈខ្សែទូរស័ព្ទហាត់ឡាញ និងជួយអាជីវកម្មដោយជួបផ្ទាល់តាមស្តង់ចល័ត ចំនួន ៧១ អាជីវកម្ម និងបានចុះទៅធ្វើទស្សនកិច្ចនៅតាមអាជីវកម្ម ១,០០០ កន្លែង ដើម្បីផ្តល់ព័ត៌មានស្តីពីកម្មវិធី និងធនធានតាមរយៈការចុះផ្សព្វផ្សាយដល់ទីកន្លែង។

គម្រោងអនាគតក្រុងឡុងប៊ិច បានចុះឈ្មោះយុវជន ៧៦៨ នាក់ តាមកម្មវិធីផ្សេងៗ ហើយយុវជនបានបំពេញម៉ោងកម្មសិក្សាការី ដែលមានប្រាក់ឧបត្ថម្ភ ចំនួន ១១០,៦៤០ ម៉ោង។

បានចូលរួមគម្រោងវាយតម្លៃអំពីលទ្ធភាពបង្កើនកន្លែងអង្គុយបណ្តោះអាសន្នក្នុងសាលមហោស្រោព នៅក្នុងបរិវេណ Queen Mary ពី ១០,០០០ កន្លែង ទៅ ១២០,០០០ កន្លែង។

ទឹកប្រាក់ជាង ៧ លានដុល្លារ ត្រូវបានវិនិយោគលើគម្រោងមូលធនធំៗ នៅមជ្ឈមណ្ឌលសន្និបាត និងកំសាន្តក្រុងឡុងប៊ិច រួមទាំងការបំពាក់កៅអីទំនើបទាន់សម័យថ្មីៗ ឆាក និងកែលម្អសំឡេងនៅក្នុងបរិវេណនោះ។

ព្រលានយន្តក្រុងឡុងប៊ិច បានរៀបចំពីបុណ្យនៃការហោះហើរគម្រប់ខួបលើកទី ១០០ របស់ខ្លួន។

បានដាក់ឲ្យដំណើរការផែនការវិនិយោគកែលម្អហេដ្ឋារចនាសម្ព័ន្ធឆ្ពោះទៅឆ្នាំ ២០២៨ ឬ Elevate 28 និងគេហទំព័រដែលផ្តល់ការលើកមុខមាត់យ៉ាងសំខាន់ ផ្នែកហេដ្ឋារចនាសម្ព័ន្ធរបស់សាលាក្រុង ដែលជាចំណុចត្រូវបង្ហាញដល់ពិភពលោកក្នុងអំឡុងព្រឹត្តិការណ៍អូឡាំពិកឆ្នាំ ២០២៨។

# សារពីអ្នកគ្រប់គ្រងក្រុង

ខ្ញុំមានសោមនស្ស ក្នុងការបង្ហាញជូនបងប្អូន នូវសំណើថវិកាឆ្នាំសារពើពន្ធ ២០២៥។ ថវិកានេះបញ្ជាក់ឡើងវិញ នូវការប្តេជ្ញារក្សាសមធម៌ និងភាពធន់នឹងវិបត្តិ ដើម្បីទ្រទ្រង់សាលាក្រុងឡុងប៊ិច និងសហគមន៍។ ស្របពេលដែលផលប៉ះពាល់ផ្នែកហិរញ្ញវត្ថុនៃជំងឺរាលដាលជាសាកល បានថមថយទៅវិញច្រើនណាស់ហើយនោះ និងស្របពេលដែលយើងត្រៀមខ្លួននៃការបិទបញ្ចប់នៃច្បាប់ស្តីពីការស្តារក្រុងឡុងប៊ិចឡើងវិញ សាលាក្រុងកំពុងផ្តោតការយកចិត្តទុក មិនមែនតែលើឱកាសដែលមានក្នុងដៃប៉ុណ្ណោះទេ គឺយើងដោះស្រាយបញ្ហាប្រឈមសំខាន់ៗផងដែរ។ ក្នុងពេលដែលយើងកំពុងសំឡឹងមើលទៅឆ្នាំសារពើពន្ធ ២០២៥ ខ្ញុំនៅតែមានការប្តេជ្ញាចិត្តខ្ពស់ ក្នុងការរៀបចំថវិការបស់ក្រុងរបស់យើង ដែលទ្រទ្រង់ដល់សហគមន៍ចម្រុះរបស់យើង និងកសាងអនាគតមួយ ដែលរាល់ពលរដ្ឋសហគមន៍យើង រស់នៅដោយសុវត្ថិភាព ភូមិឋានស្អាត និងកន្លែងមានផាសុខភាពសម្រាប់ការរស់នៅ រៀនសូត្រ ធ្វើការ លេងកំសាន្ត និងអភិវឌ្ឍខ្លួន។ គិតមកដល់ចំណុចនេះ សំណើថវិកានេះ អាចវិនិយោគដោយប្រើថវិកាសម្រាប់ប្រើការបានតែមួយដង ដោយប្រើប្រាស់ថវិកាដែលមានតែមួយដងនោះ សម្រាប់អនុវត្តគម្រោងសំខាន់ៗជាច្រើន។ ការវិនិយោគនៃសំណើថវិកាឆ្នាំសារពើពន្ធ ២០២៥ នេះផ្តោតលើការចាត់ការដោះស្រាយសេចក្តីត្រូវការបន្ទាន់បំផុត ដែលត្រូវការដោះស្រាយតែមួយដង ដោយក្នុងពេលជាមួយគ្នានេះ ខ្លួនត្រូវប្រឈមមុខនឹងកង្វះថវិកាជាអចិន្ត្រៃយ៍ពីកញ្ចប់ថវិកាទូទៅ ដែលខ្វះប្រាក់រហូតដល់ ២០,៣ លានដុល្លារ សម្រាប់ឆ្នាំសារពើពន្ធ ២០២៥។ ការវិនិយោគនៃសំណើថវិកាឆ្នាំសារពើពន្ធ ២០២៥ ទាំងនេះ អាចធ្វើទៅបាន តាមរយៈប្រាក់សន្សំសម្រាប់ប្រើប្រាស់បានតែមួយដងពីថវិកាឆ្នាំសារពើពន្ធ ២០២៤។ ទោះជាយ៉ាងនេះក្តី ក្នុងពេលដែលយើងកំពុងរៀបចំយុទ្ធសាស្ត្រ ដើម្បីសំឡឹងមើលទៅអនាគត និងដោះស្រាយបញ្ហាទាំងនេះជាអចិន្ត្រៃយ៍ ទាំងនេះតម្រូវឲ្យមានដំណោះស្រាយដែលមិនមែនសម្រាប់តែពេល។ ក្នុងពេលដែលយើងខ្វះកំណើប្រាក់ចំណូលសំខាន់ ក្នុងកញ្ចប់ថវិកាទូទៅ ការបិទបញ្ចប់ទៅវិញនៃកញ្ចប់ថវិកាដែលបានពីច្បាប់ស្តីពីការស្តារក្រុងឡុងប៊ិចឡើងវិញ និងរហូតទាល់តែមានកិច្ចការជាបន្តបន្ទាប់ ដើម្បីកំណត់ប្រភពប្រាក់ចំណូលដែលកើនឡើងជាលំដាប់ ដើម្បីទ្រទ្រង់ដល់ការកើនឡើងនៃថ្លៃចំណាយទៅការផ្តល់សេវាទូទៅរបស់រដ្ឋាភិបាល យើងត្រូវតែបន្តរក្សាឲ្យបាននូវទម្លាប់ឆ្នាំសារពើពន្ធដែលល្អ និងចៀសវាងធ្វើអ្វីមួយដែលនាំឲ្យបញ្ហាខ្វះថវិកាជាអចិន្ត្រៃយ៍របស់យើង កាន់តែអាក្រក់ជាងនេះ។ សាលាក្រុងនៅតែរក្សាការយកចិត្តទុកដាក់ លើឧបសគ្គនៃឆ្នាំសារពើពន្ធដែលនឹងចូលមកដល់ក្នុងពេលឆាប់ៗនេះ ទោះបីជាមានលទ្ធផលវិជ្ជមានពីសំណើថវិកាឆ្នាំសារពើពន្ធ ២០២៥ ដោយនៅតែផ្តោតការយកចិត្តទុកដាក់លើការវិនិយោគ ក្នុងការការពារសេវាស្នូលសម្រាប់សហគមន៍យើង។

ការពង្រឹងបន្ថែម និងប្រសិទ្ធភាពទាំងនេះ កើតមានឡើងដោយមានគោលដៅជំរុញទីក្រុងរបស់យើង ឲ្យរីកចម្រើនទៅមុខ ឆ្ពោះទៅសម្រាប់ឲ្យបាននូវចក្ខុវិស័យជាយុទ្ធសាស្ត្រសម្រាប់ឆ្នាំ ២០៣០ ដែលត្រូវបានបង្កើតឡើងដោយមានគំនិតពីសហគមន៍ និងពលរដ្ឋនៃទីក្រុងឡុងប៊ិចរបស់យើង អំពីអ្វីដែលពួកគាត់ត្រូវការជាចាំបាច់ ដើម្បីបន្តមានសុខភាពល្អ និងរស់នៅដោយមានភាពរីកចម្រើន នៅទសវត្សរ៍ខាងមុខ និងតទៅទៀត។ សំណើទាំងនេះ ក៏ពិនិត្យមើលអំពីការយកចិត្តទុកដាក់ស្តាប់មតិរបស់សហគមន៍ ដែលយើងទទួលបានពីពលរដ្ឋ កាលពីដំបូងៗ ក្នុងអំឡុងកិច្ចប្រជុំសុំយោបល់សហគមន៍ កាលពីខែ មករា ការស្ទង់មតិអំពីអាទិភាពថវិកា ដែលធ្វើក្នុងពេលដំណាលគ្នា និងចំណុចអាទិភាពដែលបានកំណត់ឃើញ ដោយក្រុមប្រឹក្សាក្រុង នៅក្នុងដំណើរការរកចំណុចអាទិភាពនាពេលថ្មីៗនេះ។

ផ្នែកសំខាន់ៗដែលមានការវិនិយោគបន្ថែម និងពង្រឹងបន្ថែម រួមមានដូចខាងក្រោម៖

- លំនៅឋាន និងភាពអនាថា
- សុវត្ថិភាពសាធារណៈ
- ឱកាសសេដ្ឋកិច្ច សមធម៌ និងភាពធន់នឹងវិបត្តិ
- ការអប់រំ
- និរន្តរភាពអាកាសធាតុ និងបរិស្ថាន
- ការដឹកជញ្ជូន និងការបង្កើតទីធ្លា
- សុខភាព និងសុខមាលភាព
- សមធម៌ផ្នែកឌីជីថល ការគិតគូរគ្រប់គ្នា និងបច្ចេកវិទ្យា
- រដ្ឋាភិបាលរបស់យើង

សៀវភៅថវិកាសហគមន៍នេះ ផ្តល់ជូននូវចំណុចសំខាន់នៃសំណើទាំងនេះ ដោយមានព័ត៌មានលម្អិត ដែលអាចរកបាននៅក្នុងសៀវភៅថវិកា ដែលមានតាមអនឡាញ។ យើងខ្ញុំសូមអរគុណបងប្អូន ដែលបានចូលរួមក្នុងដំណើរការនេះ។ ខ្ញុំរង់ចាំស្តាប់មតិរបស់បងប្អូន ក្នុងពេលដែលយើងកំពុងរៀបចំបង្ហើយថវិកានេះ។ ពេលយើងរួមគ្នា យើងអាចបន្តកសាងអនាគតមួយ ដែលរាល់ពលរដ្ឋអាចរស់នៅទីក្រុងឡុងប៊ិចដោយសុវត្ថិភាព ទីក្រុងស្អាត និងមានកន្លែងមានសុខភាព ដើម្បីរស់នៅ រៀនសូត្រ បំពេញការងារ លេងកំសាន្ត និងរីកចម្រើន។

ថំម ម៉ូឌីកា (Thomas B. Modica)
អ្នកគ្រប់គ្រងទីក្រុង

# ចំណុចសំខាន់ៗនៃសំណើថវិកាឆ្នាំសារពើពន្ធ ២០២៥

## ឱកាស និងការបង្កើតថ្មី

សាលាក្រុងនៅតែប្ដេជ្ញា ក្នុងការចូលរួម និងដោះស្រាយបញ្ហាប្រឈមទៅថ្ងៃខាងមុខ និង យកចិត្តទុកដាក់លើការច្នៃប្រឌិត និងដំណោះស្រាយបែបច្នៃប្រឌិត។ ការប្រឈមសំខាន់ខ្លះ និងឱកាសរួមមាន៖

- សេដ្ឋកិច្ចដែលធ្វើឲ្យអាកាសធាតុមានចីរភាព៖ ប្រាក់ចំណូលពីប្រេង
- គម្រោងលូតលាស់ក្រុងឡុងប៊ិច
- ប្រាក់ចំណូលថ្មី
- ការពារ និងប្រើប្រាស់ឲ្យអស់លទ្ធភាពរាល់ប្រភពប្រាក់ចំណូល
- កែលម្អ និងកែទម្រង់ដំណើរការជ្រើសរើសបុគ្គលិករបស់សាលាក្រុង



# ទិដ្ឋភាពរួមនៃឆ្នាំសារពើពន្ធ

## សាលាក្រុងជួបបញ្ហាខ្វះថវិកាសម្រាប់រយៈពេលប្រាំឆ្នាំជាប់ៗគ្នា ដែលគិតជាទឹកប្រាក់ គឺ ៦១,៥ លានដុល្លារ ដែលត្រូវដោះស្រាយ។

- យុទ្ធសាស្ត្ររបស់សាលាក្រុង គឺកាត់បន្ថយសន្សឹមៗការពឹងផ្អែកជាអចិន្ត្រៃយ៍ លើប្រាក់ចំណូលពីប្រេងជារៀងរាល់ឆ្នាំ រហូតដល់ដល់ឆ្នាំសារពើពន្ធ ២០៣០។
- កង្វះថវិកានេះ មិនអាចដោះស្រាយដោយគ្មានអន្តរាគមន៍ណាមួយនោះឡើយ។
- សាលាក្រុងបានខំប្រឹងប្រែងយ៉ាងខ្លាំង និងផ្តោតលើចំណាត់ការជាជំហានៗ ដើម្បីកំណត់រកប្រាក់ចំណូលថ្មី ដោយវិនិយោគដោយផ្ទាល់ក្នុងថវិកាឆ្នាំសារពើពន្ធ ២០២៥។
- វិធានការតាមរយៈសន្លឹកឆ្នោតនៅមូលដ្ឋាន អាចកាត់បន្ថយកង្វះថវិកានេះបាន និងផ្តល់ឱកាស ដើម្បីពង្រឹងចំណុចអាទិភាពនៃសេវាសំខាន់ៗ។
- បញ្ហាប្រឈមផ្នែកហិរញ្ញវត្ថុនៅពេលខាងមុខ ជំរុញឲ្យមានគោលនយោបាយឆ្នាំសារពើពន្ធរឹងមាំមួយ សម្រាប់ឲ្យបុគ្គលិក មានភាពសកម្ម ក្នុងការរៀបចំផែនការរបស់ខ្លួន និងបន្តប្រពៃណីនៃតម្លាភាព។

## ថវិកាឆ្នាំសារពើពន្ធ ២០២៤ បញ្ជាក់ឡើងវិញនូវភាពមានសមធម៌ និងធន់នឹងវិបត្តិរបស់ទីក្រុងរបស់យើង

ថវិកាឆ្នាំសារពើពន្ធ ២០២៥ មានទំហំទឹកប្រាក់ ៣,៦ ពាន់លានដុល្លារ ដែលមានក្រុមកញ្ចប់ថវិកា ៣៦ មុខ និងមាន ២៤ នាយកដ្ឋាន។ ក្រុមកញ្ចប់ថវិកាទូទៅ ប្រហែល ២១% នៃថវិកាសរុប និងផ្តល់សេវាស្នូលជាច្រើនរបស់សាលាក្រុង។

នៅតែបន្តប្តេជ្ញាក្នុងការផ្តល់សេវាសាធារណដែលមានគុណភាព និងវិនិយោគជួយសហគមន៍

បន្ថែមការវិនិយោគ ដែលបន្តធ្វើឲ្យកង្វះថវិកាក្នុងមូលនិធិទូទៅ នឹងត្រូវដោះស្រាយបានតាមរយៈដំណោះស្រាយតែមួយដង ដូចរៀបចំទុកពីមុន។

ធ្វើឲ្យសាលាក្រុងមានស្ថិរភាពទាំងនៅថ្ងៃនេះ ថ្ងៃស្អែក និងទៅអនាគត។

# សាលាក្រុងមានកញ្ចប់ថវិកាហិរញ្ញវត្ថុចំនួន ៣៦ មុខ

កញ្ចប់ថវិកាទូទៅ មានប្រហែល ២១ ភាគរយនៃថវិកាសរុប និងទ្រទ្រង់ដល់សេវាសំខាន់ៗជាច្រើនរបស់សាលាក្រុង។ សេវាទាំងនេះរួមមានខាងប៉ូលិស និងសេវាពន្លត់អគ្គិភ័យ ឧទ្យាន ការជួសជុលផ្លូវថ្នល់ និងចិញ្ចើមផ្លូវ និងសេវាបណ្ណាល័យ។ ប្រាក់ក្រៅពីនោះ គឺជាថវិកាភាគច្រើនរបស់សាលាក្រុង និងត្រូវបានច្បាប់កម្រិតឲ្យប្រើប្រាស់បានសម្រាប់តែសេវាជាក់លាក់ប៉ុណ្ណោះ។ ប្រាក់ទាំងនេះត្រូវបែងចែកចេញជាផ្នែកដូចខាងក្រោមនេះ៖

"មូលនិធិសហគ្រាស៖ ១.៤ ពាន់លានដុល្លារ
• ប្រាក់ទាំងនេះប្រតិបត្តិការដូចជាអាជីវកម្មមួយ ដែលយកថ្លៃសេវា ដូចជាព្រលានយន្តហោះ កំពង់ផែ និងដែនទឹក។"

"មូលនិធិទឹកជោរ៖ ២៣៣ លានដុល្លារ
• ថវិកាដែលមានការកម្រិតទាំងនេះ គឺប្រើប្រាស់ដើម្បីទ្រទ្រង់ប្រតិបត្តិការ និងគម្រោងនៅតាមតំបន់ឆ្នេរ ដែលបានថវិកាពីប្រាក់ចំណូលពីប្រេង ការផ្ទេរពីថវិកាកំពង់ផែ និងថ្លៃសមុទ្រក្នុងចំណោមប្រភេទផ្សេងទៀត។ "

"គម្រោងមូលនិធិមូលធន៖ ២១២ លានដុល្លារ
• ថវិកានេះគឺសម្រាប់ការរៀបចំផែនការ រចនា និងសំណង់ធំៗ។ ថវិកានេះបានពីថវិកាជំនួយថ្នាក់ជាតិ រដ្ឋ និងតំបន់ ថ្លៃផលប៉ះពាល់ និងការផ្ទេរពីវិធានការ A។"

"ថវិកាបានពីសេវាខាងក្នុង៖ ៧៣៣ លានដុល្លារ
• ថវិកានេះគឺសម្រាប់សេវាខាងក្នុង ដែលផ្តល់ដោយនាយកដ្ឋានផ្សេងៗរបស់សាលាក្រុង ដោយយកថ្លៃសេវាពីនាយកដ្ឋានទាំងនោះ រួមមានថវិកាសម្រាប់រថយន្ត និងថវិកាធានារ៉ាប់រង។"

"សេវាថវិកាបំណុល៖ ២៥,៦ លានដុល្លារ
• ថវិកានេះគឺសម្រាប់ទូទាត់បំណុលរដ្ឋាភិបាល។"

"ថវិកាចំណូលពិសេស៖ ២៥៦ លានដុល្លារ
• ថវិកានេះគឺសម្រាប់សកម្មភាពដែលឧបត្ថម្ភថវិកាដោយរដ្ឋ និងជំនួយថវិកាជាតិ ពន្ធដារ ឬប្រភពចំណូល ដែលកំណត់ឲ្យប្រើសម្រាប់តែគោលបំណងជាក់លាក់ ដូចជាថវិកាសម្រាប់សុខាភិបាល។"

# យល់ដឹងអំពីកញ្ចប់ថវិកាទូទៅ

ជារៀងរាល់ឆ្នាំ សាលាក្រុងមានថវិកាដើម្បីជួយទ្រទ្រង់សេវាផ្សេងៗ។ ថវិកានេះប្រែប្រួលជាប្រចាំដែរ។ ភាគច្រើននៃកញ្ចប់ថវិកាទូទៅ គឺបានមកពីការប្រមូលពន្ធ និងការចំណាយច្រើនបំផុត គឺទៅលើបុគ្គលិកដែលបម្រើសេវារបស់សាលាក្រុង។ តួលេខខាងក្រោមនេះឆ្លុះបញ្ចាំងអំពីការបែងចែកប្រាក់ចំណូល និងប្រភេទនៃការចំណាយប្រចាំឆ្នាំ។

## ប្រភពចំណូល




## ការបំបែកការចំណាយ



# ព័ត៌មានសំខាន់ៗអំពីថវិកាឆ្នាំសារពើពន្ធ ២០២៥

## លំនៅឋាន និងភាពអនាថា

**ផ្តល់លំនៅឋានសុវត្ថិភាព និងមានភាពស្មើគ្នា ដែលមានក្នុងតម្លៃថោកសមរម្យ សម្រាប់ប្រជាពលរដ្ឋគ្រប់កម្រិតប្រាក់ចំណូល។**

- បង្កើតការិយាល័យយុទ្ធសាស្រ្តនៃភាពអនាថា និងភាពជាដៃគូ នៅក្នុងការិយាល័យអ្នកគ្រប់គ្រងទីក្រុង ដើម្បីផ្តល់ការទ្រទ្រង់ដែលចាំបាច់បំផុត ដើម្បីជួយ និងអនុវត្តផែនការ និងភាពជាដៃគូដែលមានជាបន្តបន្ទាប់ពាក់ព័ន្ធនឹងផែនការយុទ្ធសាស្រ្តថ្មីស្តីពីភាពអនាថា រួមមានបន្ថែមជំនួយការមួយរូប សម្រាប់អ្នកគ្រប់គ្រងទីក្រុងដើម្បីបម្រើការជាមន្ត្រីគ្រប់គ្រងកម្មវិធី នៃការិយាល័យថ្មី និងបន្ថែមមុខតំណែងអ្នកជំនាញកម្មវិធីពីររូប ដើម្បីពន្លឿនការឆ្លើយតបផ្នែកជនអនាថារបស់សាលាក្រុង និងបង្កើនគម្រោងសម្របសម្រួល នៅទូទាំងនាយកដ្ឋានរបស់ក្រុង ដែលត្រូវប្រើប្រាស់ថវិកាសរុប ៥៤៥,០៤៨ ដុល្លារ ដែលប៉ះប៉ូវពីថវិកាជំនួយពីនាយកដ្ឋានសុខាភិបាល និងសេវាពលរដ្ឋ។

- ថវិកាសម្រាប់ប្រើការបានតែមួយដង ចំនួន ៣៧៥,០០០ ដុល្លារ នៅក្នុងកញ្ចប់ថវិកាទូទៅ របស់នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍ ដើម្បីបន្តទ្រទ្រង់ដល់កម្មវិធីបន្តមានលំនៅឋានជ្រកសម្រាប់អ្នកជួលផ្ទះនៃក្រុង ឡូស អែនជីឡែស។ ថវិកាបន្ថែមចំនួន ៦៧៥,០០០ ដុល្លារ នៅក្នុងថវិកាឆ្នាំសារពើពន្ធ ២០២៤ ដែលត្រូវរំកិល នឹងធ្វើឲ្យថវិកាសរុបកើនដល់ ១,២៥ លានដុល្លារ ដែលមានស្រាប់សម្រាប់កម្មវិធីក្នុងឆ្នាំសារពើពន្ធ ២០២៥។

- ថវិកាសម្រាប់ប្រើការបានតែមួយដង ចំនួន ៥០០,០០០ ដុល្លារ ពីកញ្ចប់ថវិកាទូទៅរបស់នាយកដ្ឋានអ្នកគ្រប់គ្រងទីក្រុង សម្រាប់មូលនិធិយុត្តិធម៌ក្រុងឡុងប៊ិច ដែលក្នុងនោះ ៣៥០,០០០ ដុល្លារ នឹងទ្រទ្រង់ដល់សេវាផ្នែកច្បាប់ និង ១៥០,០០០ ដុល្លារ សម្រាប់ទ្រទ្រង់ដល់សេវាផ្សារភ្ជាប់សហគមន៍។ ថវិកាអចិន្ត្រៃយ៍ចំនួន ៣០០,០០០ ដុល្លារ និងប្រាក់បន្ថែម ៣០០,០០០ ដុល្លារ ដែលមាននៅក្នុងថវិកាឆ្នាំសារពើពន្ធ ២០២៤ និងត្រូវរំកិល ដែលធ្វើឲ្យថវិកាសរុបនឹងមាន ១,១ លានដុល្លារ សម្រាប់មូលនិធិយុត្តិធម៌ឡុងប៊ិចក្នុងឆ្នាំសារពើពន្ធ ២០២៥ នេះ។

- បន្ថែមមុខតំណែងអ្នករៀបចំផែនការកម្រិត ៣ មួយតំណែង ពីកញ្ចប់ថវិកាសេវាអភិវឌ្ឍន៍ របស់នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍ ដែលមានទឹកប្រាក់ ១៥៥,៤៩៥ ដុល្លារ ដើម្បីបម្រើការជាអ្នកវិភាគគោលនយោបាយលំនៅឋានឈានមុខ គាំទ្រដល់គម្រោងរៀបចំផែនការជុំវិញរឿងលំនៅឋាន និងភាពអនាថា ដែលកើនឡើង។

ដើម្បីបានបញ្ជីលម្អិតមួយ សូមបងប្អូនមើលសៀវភៅថវិកាទាំងស្រុង ដែលមាននៅទីនេះ៖ longbeach.gov/finance

ថវិកាសម្រាប់ប្រើការបានតែមួយដង ចំនួន ៨២,៤៨១ ដុល្លារ ពីកញ្ចប់ថវិកាទូទៅ នៃនាយកដ្ឋានសុខាភិបាល និងសេវាពលរដ្ឋ ដើម្បីទិញរថយន្ត និងបង្កើនថវិកាសម្រាប់ការថែទាំនិងជួសជុលរថយន្តជាបន្តបន្ទាប់ ដោយមានទឹកប្រាក់ចំនួន ១១,៩៦៤ ដុល្លារ សម្រាប់អ្នកមើលការខុសត្រូវសេវាអគារ ដើម្បីបម្រើតាមទីតាំងសេវាជនអនាថា។

បន្ថែមមុខតំណែងជំនួយការផ្នែកថែទាំនិងជួសជុលកម្រិត ១ ចំនួនពីរមុខតំណែង ដែលអស់ប្រាក់សរុប ១៤១,៩៤៤ ដុល្លារ និងបន្ថែមថវិកាសម្រាប់ប្រការបានតែមួយដងចំនួន ៣៧០,៩៩៦ ដុល្លារ នៃកញ្ចប់ថវិកាប្រតិបត្តិការទឹកជោរ របស់នាយកដ្ឋានឧទ្យាន កំសាន្ត និងថែទាំសត្វសមុទ្រ ដើម្បីទ្រទ្រង់ដល់សេវាឆ្លើយតបបញ្ហាជនអនាថា ដើម្បីទិញរថយន្តធំ សម្រាប់ប្រមូលសំរាម នៅជំរុំបោះតង់របស់ជនអនាថា។ បន្ថែមលើនេះ រថយន្តនោះមានទាំងថវិកា ៥៨,២៨៤ ដុល្លារ នៃថវិកាថែទាំជួសជុលជាប្រចាំ។



# ព័ត៌មានសំខាន់ៗនៃថវិកាឆ្នាំសារពើពន្ធ ២០២៥

## សុវត្ថិភាពសាធារណៈ

**ប្តេជ្ញាធ្វើឲ្យទីក្រុងឡុងប៊ិចមានសុវត្ថិភាព តាមរយៈការផ្តល់សេវា ដែលពង្រឹងសុវត្ថិភាពសាធារណៈ ដោយមានភាពច្នៃប្រឌិត សហការ និងទំនាក់ទំនងល្អជាមួយសហគមន៍ និងកម្មវិធី។**

- ថវិកាសម្រាប់ប្រើការបានតែមួយដង ចំនួន ២០០,០០០ ដុល្លារ ពីកញ្ចប់ថវិកាទូទៅនៃនាយកដ្ឋានអ្នកគ្រប់គ្រងទីក្រុង ដើម្បីទ្រទ្រង់ដល់គម្រោងបង្ការអំពើហិង្សានៅក្រុងឡុងប៊ិច។
- ថវិកាសម្រាប់ប្រើការបានតែមួយដង ចំនួន ១,៣ លានដុល្លារ ពីកញ្ចប់ថវិកាទូទៅ នៃនាយកដ្ឋានប៉ូលិសសម្រាប់ក្រុមផ្តោតលើឧក្រិដ្ឋកម្មកម្រិតខ្ពស់ (HCFT) ដើម្បីដោះស្រាយឲ្យបានទាន់សភាពការណ៍ ចំពោះឧក្រិដ្ឋកម្មហិង្សា នៅទូទាំងទីក្រុង ដោយធ្វើយ៉ាងណាឲ្យផ្លូវរបស់យើង អត់មានកាំភ្លើង ចាប់ខ្លួនជនសង្ស័យ និងពង្រឹងសុវត្ថិភាពទូទៅ តាមរយៈការចូលរួមពីសហគមន៍ឲ្យកាន់តែស្វាហាប់ឡើង ការអប់ និងពង្រឹងកិច្ចសហប្រតិបត្តិការ។
- បង្កើនថវិកាចំនួន ១,១៧១,៤៨០ ដុល្លារ នៅក្នុងនាយកដ្ឋានពន្លត់អគ្គិភ័យ ពីកញ្ចប់ថវិកាទូទៅ សម្រាប់ទិញឧបករណ៍វេជ្ជសាស្ត្រសង្គ្រោះបន្ទាន់ ការចំណាយសម្រាប់សម្ភារៈប្រើប្រាស់នៅស្ថានីយ៍ពន្លត់អគ្គិភ័យ និងការជួសជុលថែទាំស្ថានីយ៍ពន្លត់អគ្គីភ័យ។
- ថវិកាសម្រាប់ប្រើការបានតែមួយដង ចំនួន ៥០០,០០០ ដុល្លារ ពីកញ្ចប់ថវិកាទូទៅ ក្នុងនាយកដ្ឋានពន្លត់អគ្គិភ័យ ដើម្បីទ្រទ្រង់គម្រោងសាកល្បងនៃអង្គភាពរថយន្តសង្គ្រោះ។
- ថវិកាសម្រាប់ប្រើប្រាស់បានតែមួយដង ចំនួន ២,១ លានដុលលារ ពីកញ្ចប់ថវិកាទូទៅ ក្នុងនាយកដ្ឋានពន្លត់អគ្គិភ័យ ដើម្បីទ្រទ្រង់ដល់ប្រាក់ខែសម្រាប់រើសបុគ្គលិកថ្មីផ្នែកពន្លត់អគ្គិភ័យ និងដើម្បីទ្រទ្រង់បុគ្គលិកដែលគ្មានថវិកាជំនួយ សម្ភារៈ និងថ្លៃចំណាយលើគ្រឿងបរិក្ខារ ដើម្បីប្រតិបត្តិការបណ្ឌិតសភារើសបុគ្គិកបម្រើការងារផ្នែកពន្លត់អគ្គិភ័យវគ្គ ២០២៥A ដែលមានគ្នា ៥០ នាក់ ឬ ១៦.៥ FTEs។
- ថវិកាសម្រាប់ប្រើប្រាស់បានតែមួយដង ចំនួន ២,១ លានដុលលារ ពីកញ្ចប់ថវិកាទូទៅ ក្នុងនាយកដ្ឋានពន្លត់អគ្គិភ័យ ដើម្បីទ្រទ្រង់ដល់ប្រាក់ខែសម្រាប់រើសបុគ្គលិកថ្មីផ្នែកពន្លត់អគ្គិភ័យ និងដើម្បីទ្រទ្រង់បុគ្គលិកដែលគ្មានថវិកាជំនួយ សម្ភារៈ និងថ្លៃចំណាយលើគ្រឿងបរិក្ខារ ដើម្បីប្រតិបត្តិការបណ្ឌិតសភារើសបុគ្គិកបម្រើការងារផ្នែកពន្លត់អគ្គិភ័យវគ្គ ២០២៥A ដែលមានគ្នា ៥០ នាក់ ឬ ១៦.៥ FTEs។ បន្ថែមតំណែងអ្នកពន្លត់អគ្គិភ័យមួយរូប ក្នុងទឹកប្រាក់ ២៦៩,០១១ ដុល្លារ ពីកញ្ចប់ថវិកាទូទៅ នៃនាយកដ្ឋានពន្លត់អគ្គិភ័យ ដើម្បីបម្រើការនៅអង្គភាពស៊ើបអង្កេតករណីលួចចងបង្កើតអគ្គិភ័យ ដើម្បីពង្រឹងសមត្ថភាពនៃក្រុមនេះ ឲ្យអាចឆ្លើយតបទៅនឹងហេតុការណ៍ និងការស៊ើបអង្កេតឧក្រិដ្ឋកម្មដែលកើតពីការលួចបង្កើតអគ្គិភ័យនេះ។
- បង្កើតផ្នែកស្តង់ដារជំនាញវិជ្ជាជីវៈមួយ ក្នុងចំនួនទឹកប្រាក់ ២៣៩,៩៥៨ ដុល្លារ នៅក្នុងការិយាល័យប្រតិបត្តិ នៃនាយកដ្ឋានពន្លត់អគ្គិភ័យ ដោយបានថវិកាទ្រទ្រង់ពីកញ្ចប់ថវិកាទូទៅ។ បុគ្គលិកថ្មីនេះ នឹងត្រូវទទួលខុសត្រូវ ក្នុងការស៊ើបអង្កេតករណីចោទប្រកាន់អំពីការប្រព្រឹត្តិមិនត្រឹមត្រូវ ពាក់ព័ន្ធនឹងសមាជិកណាមួយនៃនាយកដ្ឋាន និងការបណ្តុះបណ្តាលស្តង់ដារជំនាញវិជ្ជាជីវៈនៅទូទាំងនាយកដ្ឋាន ការរាយការណ៍ និងការទទួលខុសត្រូវ ដើម្បីបម្រើសហគមន៍ឲ្យបានល្អប្រសើរជាងនេះ និងឲ្យបានសមភាព និងភាពត្រឹមត្រូវ។

# ឱកាសសេដ្ឋកិច្ច សមធម៌ និងភាពធន់នឹងវិបត្តិ

## ជួយទ្រទ្រង់អាជីវកម្មក្រុងឡុងប៊ិច និងការលើកស្ទួយការអភិវឌ្ឍសេដ្ឋកិច្ច គឺជាផ្នែកមួយនៃចក្ខុវិស័យសម្រាប់ទីក្រុងដែលសម្បូរឱកាស សម្រាប់កម្មករ វិនិយោគិន និងសហគ្រិន។

- បន្ថែមមុខតំណែងបួនទៀត ទៅកញ្ចប់ថវិកាអចិន្ត្រៃយ៍ ដើម្បីជួយទ្រទ្រង់កម្មវិធីជួយអាជីវកម្ម BizCare ឲ្យកម្មវិធីនេះបន្តដំណើរការ ទោះជាអស់មូលនិធិដែលបានពីច្បាប់ស្ដីពីការស្តារក្រុងឡុងប៊ិចឡើងវិញ ដោយត្រូវប្រើថវិកា ២៨០,៧០៣ ដុល្លារ ក្នុងកញ្ចប់ថវិកាទូទៅ និង ៨២,៧៧៥ ដុល្លារ ក្នុងកញ្ចប់ថវិកាជំនួយសម្រាប់អភិវឌ្ឍសហគមន៍ នៃនាយកដ្ឋានអភិវឌ្ឍសេដ្ឋកិច្ច។

- បន្ថែមមុខតំណែងអ្នកវិភាគរដ្ឋបាលកម្រិត ២ មួយដែលមានទឹកប្រាក់សរុប ១៥៥,១៦៥ ដុល្លារ នៅក្នុងនាយកដ្ឋានអ្នកគ្រប់គ្រងទីក្រុង ដើម្បីសម្របសម្រួល និងទ្រទ្រង់ដល់គម្រោងត្រៀមសម្រាប់កីឡាអូឡាំពិកឆ្នាំ ២០២៨ របស់ក្រុង និងថវិកាជំនួយទូទាំងក្រុង។

- បង្កើតតំណែងថ្មីមួយសម្រាប់មន្ត្រីសេវាសមធម៌អាជីវកម្ម ដែលមានទឹកប្រាក់សរុប ១៨៨,៥៨៨ ដុល្លារ ក្នុងក្រុមថវិកាទូទៅនៃការិយាល័យសេវាអាជីវកម្មក្នុងនាយកដ្ឋានគ្រប់គ្រងហិរញ្ញវត្ថុ សម្រាប់ទ្រទ្រង់សកម្មភាពស្តារប្រាក់ចំណូលឡើងវិញដោយមានការវិភាគទិន្នន័យ និងសវនកម្ម។ ថ្លៃចំណាយនេះត្រូវបានប៉ះប៉ូវដោយការកើនឡើងនៃថវិកាផ្នែកអាជីវកម្មកញ្ឆា និងការជួលផ្ទះ។

- ថវិកាសម្រាប់ប្រើការតែមួយដងចំនួន ៥៦២,០០០ ដុល្លារ ក្នុងកញ្ចប់ថវិកាប្រតិបត្តិការទឹកជោរ នៃនាយកដ្ឋានអភិវឌ្ឍន៍សហគមន៍ សម្រាប់រៀបចំផែនការចំណាយផ្នែកពិគ្រោះយោបល់ ដែលត្រូវការជាចាំបាច់ ដើម្បីបំពេញការសិក្សាអំពីចក្ខុវិស័យ សម្រាប់ផែនការតំបន់ឆ្នេរនៃទីប្រជុំជនក្រុង ដែលនឹងលើកមុខមាត់តំបន់ឆ្នេរកណ្ដាលក្រុងនេះ ឲ្យក្លាយជាទីតាំងប្រចាំតំបន់ និងជាគំរូសម្រាប់ផែនការបង្កើតឲ្យមានឆ្នេរសមុទ្រលំដាប់ពិភពលោក។

### គម្រោងឱកាសតំបន់ឆ្នេរ/លូតលាស់ក្រុងឡុងប៊ិច

ផែនការដែលជំរុញការអភិវឌ្ឍសេដ្ឋកិច្ចនៃឧស្សាហកម្មសំខាន់ៗរបស់ទីក្រុងឡុងប៊ិច ដូចជាវិស័យអវកាស និងទេសចរណ៍ និងដើម្បីរិះរកប្រភពចំណូលច្រើនយ៉ាង។

# ព័ត៌មានសំខាន់ៗអំពីសំណើថវិកាឆ្នាំសារពើពន្ធ ២០២៥

## ការដឹកជញ្ជូន និងការបង្កើតទីធ្លា

### ការវិនិយោគជាយុទ្ធសាស្ត្រ និងគិតគូរទៅអនាគត ដែលនឹងប្រើប្រាស់ធនធានដែលមានបច្ចុប្បន្នឲ្យអស់ពីលទ្ធភាព សម្រាប់ប្រយោជន៍អនាគតជាបន្ត ពាក់ព័ន្ធនឹងការដឹកជញ្ជូន និងមូលដ្ឋានគ្រឹះនៃហេដ្ឋារចនាសម្ព័ន្ធក្រុង។

បន្ថែមទឹកប្រាក់ FTEs ចំនួន ៩០៥,០៥២ ដុល្លារ ក្នុងប្រាក់ទុននៃកញ្ចប់ថវិកាក្រុមគម្រោងក្នុងនាយកដ្ឋានសាធារណការ ដើម្បីបង្កើតកម្មវិធីបេតុងក្នុងអគារ ដើម្បីឲ្យបុគ្គលិកសាលាក្រុងបង្កើតជំនាញក្នុងការវាយកម្ទេចអគារ ចាក់បេតុង និងបង្ហើយកិច្ចការផ្នែកបេតុងនេះ ដើម្បីដោះស្រាយបញ្ហាកកស្ទះកិច្ចការចាក់បេតុង ដែលនៅសល់ជាច្រើន ដែលត្រូវការធ្វើឲ្យហើយនៅទូទាំងក្រុង ព្រមទាំងឆ្លើយតបទៅនឹងតម្រូវចាំបាច់ខ្លាំងផ្នែកការងារចាក់បេតុងនេះ ឲ្យបានទាន់ពេលវេលា និងសមស្រប។

ថវិកាសម្រាប់ប្រើការបានតែមួយដងចំនួន ១០០,០០០ ដុល្លារ ក្នុងកញ្ចប់ក្រុមថវិកាសម្រាប់ផ្សាយពាណិជ្ជកម្មពិសេសេ និងផ្សព្វផ្សាយ នៅនាយកដ្ឋានអ្នកគ្រប់គ្រងទីក្រុង ដើម្បីទ្រទ្រង់ដល់កម្មវិធី Beach Streets នៃតំបន់ភាគខាងលិច។

## ផែនការសកម្មភាពអាកាសធាតុ (CAP)

ក្នុងឆ្នាំ ២០២២ សាលាក្រុងបានអនុម័តផែនការសកម្មភាពអាកាសធាតុដែលមានធ្លាប់មានពីមុនមក។ ផែនការសកម្មភាពអាកាសធាតុរបស់ក្រុងឡុងប៊ិច (LB CAP) នេះ ផ្តល់ជាក្រមខណ្ឌមួយ សម្រាប់បង្កើត ឬកែលម្អគោលនយោបាយ កម្មវិធី និងការអនុវត្ត និងការលើកទឹកចិត្ត សម្រាប់ពលរដ្ឋក្រុងឡុងប៊ិច និងអាជីវកម្ម ក្នុងការកាត់បន្ថយផលប៉ះពាល់នៃឧស្ម័នផ្ទះកញ្ចក់ (GHG) និងជួយធានាឲ្យសហគមន៍ទទួលបានការពារកាន់តែប្រសើរជាងមុន ពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។

គោលដៅសំខាន់បំផុតមួយរបស់ផែនការ LB CAP នេះ គឺសម្រាប់ឲ្យសាលាក្រុង ឈានទៅសម្រេចជោគជ័យ ក្នុងការក្លាយខ្លួនជាទីក្រុងដែលគ្មានជាតិកាបូនក្នុងខ្យល់ក្នុងកម្រិតកណ្តាលមួយ ត្រឹមឆ្នាំ ២០៤៥ ដោយមានគោលដៅកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ ឲ្យបាន ៤០% ត្រឹមឆ្នាំ ២០៣០។ ដើម្បីសម្រេចគោលដៅនេះ ផែនការ LB CAP មានចែងលម្អិតអំពីចំណាត់ការ ដែលត្រូវអនុវត្តនៅតាមវិស័យជាច្រើន ដើម្បីប្រយុទ្ធប្រឆាំងនឹងបញ្ហាដែលពាក់ព័ន្ធនឹងកំដៅក្តៅខ្លាំងហួសប្រមាណ គុណភាពខ្យល់អាកាស គ្រោះរាំងស្ងួត ការឡើងកម្រិតទឹកសមុទ្រ និងជំនន់ អគារ និងថាមពល ការដឹកជញ្ជូន និងកាកសំណល់។

# ការដឹកជញ្ជូន និងការបង្កើតទីធ្លា

## ការវិនិយោគជាយុទ្ធសាស្ត្រ និងគិតគូរទៅអនាគត ដែលនឹងប្រើប្រាស់ធនធានដែលមានបច្ចុប្បន្នឲ្យអស់ពីលទ្ធភាព សម្រាប់ប្រយោជន៍អនាគតជាបន្ត ពាក់ព័ន្ធនឹងការដឹកជញ្ជូន និងមូលដ្ឋានគ្រឹះនៃហេដ្ឋារចនាសម្ព័ន្ធក្រុង។

- បន្ថែមទឹកប្រាក់ FTEs ចំនួន ៩០៥,០៥២ ដុល្លារ ក្នុងប្រាក់ទុននៃកញ្ចប់ថវិកាក្រុមគម្រោងក្នុងនាយកដ្ឋានសាធារណការ ដើម្បីបង្កើតកម្មវិធីបេតុងក្នុងអគារ ដើម្បីឲ្យបុគ្គលិកសាលាក្រុងបង្កើតជំនាញក្នុងការវាយកម្ទេចអគារចាក់បេតុង និងបង្វើយកិច្ចការផ្នែកបេតុងនេះ ដើម្បីដោះស្រាយបញ្ហាកកស្ទះកិច្ចការចាក់បេតុង ដែលនៅសល់ជាច្រើន ដែលត្រូវការធ្វើឲ្យហើយនៅទូទាំងក្រុង ព្រមទាំងឆ្លើយតបទៅនឹងតម្រូវចាំបាច់ខ្លាំងផ្នែកការងារចាក់បេតុងនេះ ឲ្យបានទាន់ពេលវេលា និងសមស្រប។

- ថវិកាសម្រាប់ប្រើការបានតែមួយដងចំនួន ១០០,០០០ ដុល្លារ ក្នុងកញ្ចប់ក្រុមថវិកាសម្រាប់ផ្សាយពាណិជ្ជកម្មពិសេសេ និងផ្សព្វផ្សាយ នៅនាយកដ្ឋានអ្នកគ្រប់គ្រងទីក្រុង ដើម្បីទ្រទ្រង់ដល់កម្មវិធី Beach Streets នៃតំបន់ភាគខាងលិច។

- ថវិកាសម្រាប់ប្រើការបានតែមួយដងចំនួន ៥០០,០០០ ដុល្លារ នៃក្រុមថវិកាទូទៅ ផ្នែកនាយកដ្ឋានសាធារណការ សម្រាប់កែលម្អការដឹកជញ្ជូនឲ្យមានសុវត្ថិភាព។

- បន្ថែមបុគ្គលិកត្រួតពិនិត្យការចតយានយន្តចំនួនបួន ពីកញ្ចប់ថវិកាទូទៅ ផ្នែកសាធារណការ សម្រាប់ការពង្រឹងការចតយានយន្តបន្ថែមនៅទូទាំងទីក្រុង ដើម្បីបង្ការការចតយានយន្តដោយខុសច្បាប់។

- “បន្ថែម ៩.២៦ FTEs ទៅក្នុងកញ្ចប់ថវិកាគម្រោងទុនក្នុងនាយកដ្ឋានសាធារណការ ដើម្បីបង្កើតកម្មវិធីចែករំលែកកង់ប្រើក្នុងផ្ទះ សម្រាប់ការគ្រប់គ្រង និងប្រតិបត្តិការនៃការចែករំលែកកង់ប្រើជាសាធារណៈចំនួន ១,៤០០ កង់ ដែលមានចែកចាយនៅតាមទីតាំងចែករំលែកកង់ ១០០ កន្លែង ដែលកំពុងពង្រីកទៅទីតាំងកាន់តែច្រើនបន្ថែមទៀត ដើម្បីផ្តល់ជម្រើសក្នុងការប្រើប្រាស់កង់អគ្គិសនីឲ្យបានកាន់តែទូលំទូលាយ”។

# ចំណុចសំខាន់ៗនៃថវិកាឆ្នាំសារពើពន្ធ ២០២៥

## គម្រោងកែលម្អក្រុងឆ្ពោះទៅឆ្នាំ ២០២៨ ឬ Elevate ‘28

កាលពីឆ្នាំសារពើន្ធ ២០២៤ សាលាក្រុងបានពង្រីកផែនការឆ្នាំសារពើពន្ធ ២០២៣ ដល់ ២០២៧ ដោយបន្ថែមមូលនិធិ ២១៤ លានដុល្លារ ដើម្បីទ្រទ្រង់បីផ្នែកបន្ថែម រួមមានផ្នែកកេរដំណែលអូឡាំពិក ២០២៨ ការវិនិយោគជួយសហគមន៍និងវប្បធម៌ និង គម្រោងឧទ្យាន Gold Medal Park Refresh--និងដាក់ឈ្មោះផែនការនេះថា គម្រោងវិនិយោគកែលម្អហេរដ្ឋារចនាសម្ព័ន្ធ ឆ្ពោះទៅឆ្នាំ ២០២៨ ឬ the Elevate ’28

ផែនការវិនិយោគកែលម្អហេដ្ឋារចនាសម្ព័ន្ធឆ្ពោះទៅឆ្នាំ ២០២៨ ឬ the Elevate ‘28 នេះផ្តល់នូវផែនការមួយ ដើម្បីស្តារហេដ្ឋារចនាសម្ព័ន្ធក្រុងឡុងប៊ិច ត្រៀមរៀបចំទីក្រុងនេះ ដើម្បីបង្ហាញពិភពលោក ក្នុងអំឡុងព្រឹត្តិការណ៍កីឡាអូឡាំពិកឆ្នាំ ២០២៨ និង វិនិយោគលើគម្រោងជួយស្តារតំបន់ភាគខាងលិច និងបន្តកែលម្អ និងពង្រឹងឧទ្យានទាំងឡាយក្នុងក្រុង ច្រកសំខាន់ៗ និងតំបន់ បម្រើសេវាទេសចរ។ គិតត្រឹមថវិកាឆ្នាំសារពើពន្ធ ២០២៥ គម្រោងប្រាំឆ្នាំ ទទួលបានថវិកាទ្រទ្រង់ចំនួន ៣០៦ លានដុល្លារ ពីកញ្ចប់ថវិកាវិធានការ A និង ៦២២ លានដុល្លារ ពីប្រភពធនធានដទៃទៀត រួមតាំងថវិកា Metro ពន្ធលើសាំង SB-1 និងថវិកាជំនួយ ដែលរំពឹងទុក ដែលមានទឹកប្រាក់ ៩២៨ លានដុល្លារ ដែលគ្រោងសម្រាប់ទ្រទ្រង់ការស្តារហេដ្ឋារចនាសម្ព័ន្ធ។

## គម្រោងកែលម្អក្រុងឆ្ពោះទៅឆ្នាំ ២០២៨ ឬ Elevate ‘28

កម្មវិធីកែលម្អប្រាក់ទុនក្នុងសំណើថវិកាឆ្នាំសារពើពន្ធ ២០២៥ មានទឹកប្រាក់ ២២១.៨ លានដុល្លារ ដោយមិនទាន់គិតពីនាយកដ្ឋានកំពង់ផែ និងប្រភពផ្សេងៗទៀត។ មានបញ្ចូលក្នុងកម្មវិធីកែលម្អប្រាក់ទុននេះដែរ មានថវិកាចំនួន ១២.៥ លានដុល្លារ ពីមូលនិធិវិធានការ A ដែលសម្រាំងទុកដើម្បីស្តារហេដ្ឋារចនាសម្ព័ន្ធក្រុងដែលចាស់ និងខូចខាត និងមានថវិកាបន្ថែម ៦៥.៥ លានដុល្លារ ពីកម្មវិធីភាគហ៊ុននៃវិធានការ A ដែលមានបញ្ចូលក្នុងផែនការស្តារហេដ្ឋារចនាសម្ព័ន្ធក្រុងឆ្ពោះទៅឆ្នាំ ២០២៨ ដូចមានរៀបរាប់ខាងលើផងដែរ។



For a comprehensive list, please see the full budget book available here: longbeach.gov/finance

## សុខភាព ស្ថានភាពផ្លូវចិត្ត និងសុខមាលភាព

ធានាយ៉ាងណាពលរដ្ឋនៅគ្រប់ភូមិ មានធនធានដែលពួកគាត់ត្រូវការចាំបាច់ ដើម្បីជីវភាពរស់នៅប្រកបដោយសុខភាពល្អ ទាំងផ្លូវកាយ ផ្លូវចិត្ត និងការប្រាស្រ័យទាក់ទងក្នុងក្នុងសង្គម។

- បន្ថែមតំណែងមន្ត្រីសមធម៌សុខភាពមួយ និងតំណែងអ្នកជំនាញសុខភាពសាធារណៈមួយដែរ ដោយត្រូវប្រើប្រាស់ថវិកា ៣៣១,២៨៩ ដុល្លារ ក្នុងក្រុមកញ្ចប់ថវិកាទូទៅ ផ្នែកនាយកដ្ឋានសុខាភិបាល និងសេវាពលរដ្ឋ ដើម្បីជួយដល់កម្មវិធីសមធម៌សុខភាពនេះ។
- បន្ថែមមុខតំណែងអ្នកវិភាគផ្នែកសុខភាពកម្រិត ២ ពីរមុខតំណែង ដើម្បីជួយកម្មវិធីអ្នកលក់ដូរតាមចិញ្ចើមផ្លូវ ក្នុងនាយកដ្ឋានសុខាភិបាល និងសេវាពលរដ្ឋ ដែលប្រើថវិកាសរុប ៣១៩,៣៧៨ ដុល្លារ ពីក្រុមថវិកាទូទៅ។
- បន្ថែមមុខតំណែងប្រតិបត្តិករឧបករណ៍កម្រិត ២ ដើម្បីបង្កើនសមាជិកក្រុមបោសសំអាតក្រុង ដោយប្រើថវិកាចំនួន ៩៦,៨២៥ ដុល្លារ និងថវិកាសម្រាប់ប្រើការតែមួយដង ចំនួន ៨០,៩៨០ ដុល្លារ ដើម្បីទិញម៉ាស៊ីនរាស់សំរាម ដើម្បីជួយដល់ក្រុមសំអាតក្រុង ដើម្បីបង្កើនសមត្ថភាពការងារសំអាតតំបន់ឆ្នេរ។

## ការអប់រំ

យើងប្ដេជ្ញាគិតគូរដល់អនាគតរបស់កុមារនៅគ្រប់ភូមិ ដើម្បីឲ្យពួកគេទទួលបានសេវាអប់រំប្រកបដោយគុណភាព ការថែទាំកុមារ កម្មវិធីក្រោយម៉ោងសាលា ការអប់រំក្រោយថ្នាក់វិទ្យាល័យ និងត្រៀមខ្លួនពួកគេ ដើម្បីអាចរកការងារធ្វើបានដោយជោគជ័យ។

- ថវិកាប្រើការបានតែមួយដងពីវិធានការ US ដែលមានទឹកប្រាក់ ៣០,០០០ ពីក្រុមកញ្ចប់ថវិកាទូទៅ នៃនាយកដ្ឋានសុខាភិបាល និងសេវាពលរដ្ឋ ដើម្បីជួយដល់ពិធីបុណ្យយុវជន។
- ថវិកាប្រើការបានតែមួយដងពីវិធានការ US ដែលមានទឹកប្រាក់ ៤០០,៩៤២ ដុល្លារ នៃនាយកដ្ឋានសុខាភិបាល និងសេវាពលរដ្ឋ សម្រាប់ថវិកាជួយសហគមន៍ និងប្រាក់លើកទឹកចិត្ត សម្រាប់ការអភិវឌ្ឍយុវជន។
- បន្ថែមតំណែងជំនួយការផ្នែកថែទាំនិងជួសជុលទូទៅ ដែលប្រើថវិកា ៩៥,១៦៥ ដុល្លារ ក្នុងក្រុមកញ្ចប់ថវិកាទូទៅ នៃនាយកដ្ឋានបណ្ណាល័យ សិល្បៈ និងវប្បធម៌ ដើម្បីផ្ដល់សេវាក្នុងអគារ រួមទាំងគម្រោងសាងសង់ និងការថែទាំជួសជុលអគារ។
- បង្កើនថវិកា ២០៣,៦៨៧ ដុល្លារ ដើម្បីទ្រទ្រង់ដល់វិធានការសុវត្ថិភាព នៅតាមបណ្ណាល័យសាធារណៈក្រុងឡុងបិច ដោយផ្ដោតលើសាខាបណ្ណាល័យ Mark Twain Neighborhood។

# ចំណុចសំខាន់ៗនៃថវិកាឆ្នាំសារពើពន្ធ ២០២៥

## សមធម៌ផ្នែកឌីជីថល ការគិតគូរមនុស្សគ្រប់គ្នា និងបច្ចេកវិទ្យា

រដ្ឋាភិបាលរបស់យើង- លទ្ធភាពរបស់សាលាក្រុងក្នុងការផ្តល់សេវានានា ទៅតាមការចាំបាច់នោះ គឺធ្វើឲ្យសាលាក្រុងមានភាពធន់នឹងវិបត្តិប្រចាំឆ្នាំសារពើពន្ធ មានបុគ្គលិកគ្រប់គ្រាន់ មានបច្ចេកវិទ្យាទំនើបទាន់សម័យ បន្តរៀនសូត្រ មានធនធានទ្រទ្រង់គ្រប់គ្រាន់ ដែលស្របតាមចំណុចអាទិភាព និងមានតម្លាភាព និងមានការចូលរួមពីសហគមន៍ពេញលេញ។

- បន្ថែមថវិកា ១ លានដុល្លារ ក្នុងកញ្ចប់ក្រុមថវិកាទូទៅ នៃនាយកដ្ឋានបច្ចេកវិទ្យា និងនវានុវត្តន៍ សម្រាប់សន្តិសុខតាមប្រព័ន្ធអ៊ិនធើណិត។

- ថវិកាសម្រាប់ប្រើការបានតែមួយដង ក្នុងទឹកប្រាក់ ៧០០,០០០ ដុល្លារ ក្នុងកញ្ចប់ថវិកាសេវាទូទៅ នៃនាយកដ្ឋានបច្ចេកវិទ្យា និងនវានុវត្តន៍ ដើម្បីរចនាឡើងវិញ រៀបចំគេហទំព័រឡើងវិញ និងផ្សព្វផ្សាយជាថ្មីនៃគេហទំព័រសាធារណៈរបស់ក្រុងឡុងប៊ិច Long_Beach.gov ដែលថវិកានេះប៉ះប៉ូវដោយថវិកាសម្រាប់សេចក្តីត្រូវការខ្លាំងបំផុត។

## រដ្ឋាភិបាលរបស់យើង

រដ្ឋាភិបាលរបស់យើង- លទ្ធភាពរបស់សាលាក្រុងក្នុងការផ្តល់សេវានានា ទៅតាមការចាំបាច់នោះ គឺធ្វើឲ្យសាលាក្រុងមានភាពធន់នឹងវិបត្តិប្រចាំឆ្នាំសារពើពន្ធ មានបុគ្គលិកគ្រប់គ្រាន់ មានបច្ចេកវិទ្យាទំនើបទាន់សម័យ បន្តរៀនសូត្រ មានធនធានទ្រទ្រង់គ្រប់គ្រាន់ ដែលស្របតាមចំណុចអាទិភាព និងមានតម្លាភាព និងមានការចូលរួមពីសហគមន៍ពេញលេញ។

- បន្ថែមមុខតំណែងជំនួយការអ្នកវិភាគផ្នែករដ្ឋបាលកម្រិត ២ ពីក្រុមកញ្ចប់ថវិកាទូទៅ នៅនាយកដ្ឋានគ្រប់គ្រងហិរញ្ញវត្ថុ ដើម្បីគាំទ្រការវិភាគទិន្នន័យទាំងបរិមាណ និងគុណភាព និងរាយការណ៍អំពីលំហូរប្រាក់ចំណូលច្រើនប្រភពទូទាំងក្រុង (ឧទាហរណ៍ ប្រាក់ចំណូលពីការពិន័យក្នុងការចតខុស និងប្រាក់ចំណូលពីរថយន្តសង្គ្រោះបន្ទាន់) ដែលត្រូវប្រើប្រាស់ទឹកប្រាក់ ១២០,៧៩៨ ដុល្លារ ដែលបានប៉ះប៉ូវពីការលុបចោលមុខតំណែងផ្សេងៗទៀតនៅក្នុងនាយកដ្ឋាននេះ។

- ថវិការសម្រាប់ប្រើការបានតែមួយដង ចំនួន ៥០០,០០០ ដុល្លារ និងថវិកាអចិន្ត្រៃយ៍ចំនួន ៤៥,០០០ ដុល្លារ ពីផ្នែកនៃក្រុមកញ្ចប់ថវិកាសម្រាប់អត្ថប្រយោជន៍បុគ្គលិក ក្នុងនាយកដ្ឋានធនធានមនុស្ស សម្រាប់សេវាជាប់កិច្ចសន្យា ដើម្បីជួយបញ្ហាកកស្ទះការងារក្នុងការចាត់ចំណាត់ថ្នាក់ និងសិក្សាអំពីប្រាក់សំណង។

- ថវិកាសម្រាប់ប្រើការបានតែមួយដង ក្នុងទឹកប្រាក់ ៥០,០០០ ដុល្លារពីក្រុមកញ្ចប់ថវិកាទូទៅ នៃនាយកដ្ឋានអ្នកគ្រប់គ្រងទីក្រុង ដើម្បីជួយទ្រទ្រង់វគ្គបណ្តុះបណ្តាលអំពីសមធម៌ផ្នែកពូជសាសន៍ ដែលធ្វើជាបន្តបន្ទាប់ រួមមានកម្មវិធី រចនា និងអនុវត្ត គោលនយោបាយ និងសេវាផ្សេងៗ ដោយគិតគូរពីសមធម៌។

ដើម្បីបានបញ្ជីលម្អិតមួយ សូមបងប្អូនមើលសៀវភៅថវិកាទាំងស្រុង ដែលមាននៅទីនេះ៖ longbeach.gov/finance

- ថវិកាដែលប្រើការបានតែមួយដង ចំនួន ៣៥០,០០០ ដុល្លារ ពីក្នុងក្រុមកញ្ចប់ថវិកាសេវាទូទៅ នៃនាយកដ្ឋានបច្ចេកវិទ្យា និងនវានុវត្តន៍ ដើម្បីកែលម្អកម្មវិធី Go Long Beach ឲ្យប្រសើរឡើង ដូចជាការកែលម្អផ្ទាំងបង្ហាញកម្មវិធីសម្រាប់ងាយស្រួលប្រើប្រាស់ និងមុខងារងាយស្រួលប្រើប្រាស់ផ្សេងទៀត។

- បន្ថែមមុខតំណែងជំនួយការអ្នកវិភាគរដ្ឋបាលកម្រិត ២ ក្នុងទឹកប្រាក់ ៩០,៦១៥ ដុល្លារ នៅនាយកដ្ឋានអភិវឌ្ឍន៍សហគមន៍ ដើម្បីបម្រើការជាមន្ត្រីសម្របសម្រួលរវាងក្រុមប្រឹក្សាក្រុង និងនាយកដ្ឋានអភិវឌ្ឍន៍សហគមន៍។

- បន្ថែមមុខតំណែងជំនួយការអ្នកវិភាគរដ្ឋបាលកម្រិត ២ និងដំឡើងមុខតំណែងជំនួយការរដ្ឋបាលកម្រិត ២ មួយទៀត ដោយប្រើប្រាស់ថវិកា ១៣៦,០៧២ ដុល្លារ ពីក្រុមកញ្ចប់ថវិកាទូទៅ ពីនាយកដ្ឋានសាធារណការ ដើម្បីបម្រើការជាមន្ត្រីសម្រាបសម្រួលជាមួយក្រុមប្រឹក្សាក្រុង និងដើម្បីធានាការឆ្លើយតបល្អប្រសើរជាងនេះ និងធានាភាពស៊ីសង្វាក់ និងការដោះស្រាយបញ្ហាបានលឿនជាងមុន និងទំនាក់ទំនងល្អជាងមុន ដោយសារតែមុខតំណែងនេះពាក់ព័ន្ធនឹងសំណើសុំសេវា។

- ថវិកាចំនួន ២៩៤,២២២ ដុល្លារ ពីក្រុមកញ្ចប់ថវិកាទូទៅ នៃនាយកដ្ឋានអ្នកគ្រប់គ្រងទីក្រុង ដើម្បីជួយទ្រទ្រង់កម្មវិធីផ្តល់សេវាបកប្រែ (LAP) សម្រាប់កិច្ចប្រជុំសាលាក្រុង និងកម្មវិធីផ្សេងៗ ការបកប្រែឯកសារ និងសេវាបកប្រែតាមទូរស័ព្ទ។



# ចំណុចសំខាន់ៗនៃថវិកាឆ្នាំសារពើពន្ធ ២០២៥

### ច្បាប់ស្ដីពីការស្តារក្រុងឡុងប៊ិចឡើងវិញ

កាលពីខែ មីនា ឆ្នាំ ២០២១ ក្រុមប្រឹក្សាក្រុងឡុងប៊ិច បានអនុម័តច្បាប់ស្ដីពីការស្តារក្រុងឡុងប៊ិចឡើងវិញ ដែលច្បាប់នេះចែងលម្អិតអំពីផែនការដំបូងក្នុងកម្រិតជាតិ ក្នុងការស្តារទីក្រុងឡើងវិញ ក្រោយពីមានវិបត្តិដោយសារជំងឺកូវីដ-១៩។ ច្បាប់នេះមានចែងអំពីគោលបំណងស្តារសេដ្ឋកិច្ច និងសុខភាពសម្រាប់ទីក្រុងឡុងប៊ិច។

ដោយសារច្បាប់នេះ យើងមានថវិកាសរុប ២៩៦,៩ លានដុល្លារ ដើម្បីទ្រទ្រង់ដល់កម្មវិធីជាង ៨០ មុខដូចខាងក្រោម៖

| | | |
|---|---|---|
| ការស្តារសេដ្ឋកិច្ច ឡើងវិញ៖ ៦៩,៩ លានដុល្លារ | សុខភាព និងសហគមន៍ មានសុវត្ថិភាព៖ ១៥០,៧ លានដុល្លារ | ធានាអនាគតរបស់ក្រុង យើង៖ ៧៦,៣ លាន ដុល្លារ |

ដើម្បីធ្វើឲ្យច្បាប់ស្ដីពីការស្តារក្រុងឡុងប៊ិច មានភាពស៊ីសង្វាក់គ្នាទៅនឹងការប្រើប្រាស់មូលនិធិពីច្បាប់ស្ដីពីផែនការសង្គ្រោះអាមេរិកឡើងវិញនៅកម្រិតជាតិ ច្បាប់ស្ដីពីការស្តារក្រុងឡុងប៊ិចឡើងវិញនេះ នឹងត្រូវបិទបញ្ចប់ត្រឹមថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២៤។

កម្មវិធីនៃច្បាប់ស្ដីពីការស្តារក្រុងឡុងប៊ិចឡើងវិញជាបន្តបន្ទាប់ទៅនេះ គឺត្រូវបានទ្រទ្រង់ដោយថវិកាប្រើការជាអចិន្ត្រៃយ៍ ក្នុងឆ្នាំសារពើពន្ធ ២០២៥ ក្នុងកម្រិតកាត់បន្ថយមួយ ដែលនៅតែបន្តឲ្យមានសេវាផ្សេងៗតទៅទៀត ប៉ុន្តែក្នុងស្ថានភាពកាត់បន្ថយទំហំរបស់វា។

1. កម្មវិធី BeSAFE (ឧទ្យាន ការកំសាន្ត និងថែទាំសត្វសមុទ្រ)៖ ២៩៦,០០០ ដុល្លារ ដែលប៉ះប៉ូវទាំងស្រុងដោយកាត់បន្ថយកម្មវិធីដូចគ្នានេះ ដែលមិនត្រូវការមានបុគ្គលិក។
2. កម្មវិធីជួយអាជីវកម្ម BizCare (នាយកដ្ឋានអភិវឌ្ឍន៍សេដ្ឋកិច្ច និងសាធារណការ)៖ ២៨១,០០០ ដុល្លារ ការអភិវឌ្ឍសេដ្ឋកិច្ច និង ៥០,០០០ ដុល្លារ សម្រាប់កិច្ចការសាធារណការ។
3. មន្ត្រីសេវាសមធម៌អាជីវកម្ម (នាយកដ្ឋានគ្រប់គ្រងហិរញ្ញវត្ថុ)៖ ១៨៩,០០០ ដុល្លារ
4. កម្មវិធីមូលនិធិសមធម៌សុខភាព (នាយកដ្ឋានសុខាភិបាល និងសេវាពលរដ្ឋ)៖ ៣៣១,០០០ ដុល្លារ
5. កម្មវិធីផ្តល់សេវាបកប្រែ (នាយកដ្ឋានអ្នកគ្រប់គ្រងទីក្រុង)៖ ២៩៤,០០០ ដុល្លារ
6. កម្មវិធីសមាហរណកម្ម (នាយកដ្ឋានសុខាភិបាល និងសេវាពលរដ្ឋ)៖ ១៥៧,០០០ ដុល្លារ
7. អនុលោមភាពនៃការគ្រប់គ្រងហានិភ័យសម្រាប់អ្នកលក់ (នាយកដ្ឋានធនធានមនុស្ស)៖ ១៥៧,០០០ ដុល្លារ
8. ការលក់ដូរតាមចិញ្ចើមផ្លូវ (នាយកដ្ឋានគ្រប់គ្រងហិរញ្ញវត្ថុ និងសុខាភិបាល និងសេវាពលរដ្ឋ)៖ ៤៧២,០០០ ដុល្លារ

ដើម្បីបានបញ្ជីលម្អិតមួយ សូមបងប្អូនមើលសៀវភៅថវិកាទាំងស្រុង ដែលមាននៅទីនេះ៖ longbeach.gov/finance

ជាចុងក្រោយ កម្មវិធីដែលបានថវិកាជំនួយពីច្បាប់ស្តីពីការស្តារក្រុងឡុងប៊ិចឡើងវិញដូចតទៅនេះ អាចត្រូវចាប់ផ្តើមអនុវត្ត នៅពេលក្រោយ នៃកាលវិភាគកំណត់នៃច្បាប់នេះ ដែលនៅមានថវិកាសេសសល់ ឬកំពុងផ្តល់សេវាដែលបន្តត្រូវការ។ មូលនិធិពីកម្មវិធីនៃច្បាប់ស្តីពីការស្តារក្រុងឡុងប៊ិចឡើងវិញដែលមិនទាន់បានប្រើប្រាស់ នៅចុងបញ្ចប់នៃឆ្នាំសារពើពន្ធ ២០២៤ នឹងត្រូវយកមកប្រើប្រាស់ឡើងវិញ ដើម្បីទ្រទ្រង់ដល់សេវាដូចតទៅនេះ នៅក្នុងថវិកាឆ្នាំសារពើពន្ធ ២០២៥។

1. បុគ្គលិកសាលាក្រុងឡុងប៊ិច--ការផ្តល់ឱវាទដល់យុវជន
2. គម្រោងសាកល្បងឆ្លើយតបវិបត្តិសហគមន៍
3. ការអប់រំកុមារវ័យដំបូងៗ--បង្កើនលទ្ធភាពដែលសហគមន៍ប្រើប្រាស់បណ្ណាល័យ សិល្បៈ និងវប្បធម៌
4. ការអប់រំកុមារវ័យដំបូងៗ--កែលម្អបរិក្ខារសុខាភិបាលភាគខាងលិច
5. កម្មសិទ្ធិផ្ទះលើកដំបូង (បន្ថែមជំនួយជួយប្រាក់តម្កល់ទិញផ្ទះ)
6. គម្រោងសុវត្ថិភាពអាហារូបត្ថម្ភ--ផ្សារចល័តអាហារសុខភាព
7. សមិទ្ធិសមាហរណកម្ម
8. ច្រកឆ្លងកាត់ដោយសុវត្ថិភាព--កម្មវិធីភូមិឃុំមានសុវត្ថិភាព
9. ការលក់ដូរតាមចិញ្ចើមផ្លូវដោយជោគជ័យ (ការគាំពារអ្នកលក់ដូរតាមចិញ្ចើមផ្លូវ)
10. ការបង្កើតកម្មវិធីសុខភាពយុវជន និងសុវត្ថិភាព--សេវាចល័ត



# សូមបងប្អូនចូលរួមក្នុងការរៀបចំថវិកាឆ្នាំសារពើពន្ធ ២០២៥៖

- សូមចូលរួមសវនាការអំពីថវិកា នៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សាក្រុង
- សូមចូលរួមកិច្ចប្រជុំរបស់គណៈកម្មាធិការត្រួតពិនិត្យថវិកា
- សូមចូលរួមកិច្ចប្រជុំសុំយោបល់សហគមន៍អំពីបញ្ហាថវិកា
- សូមបំពេញប័ណ្ណបញ្ចេញមតិឌីជីថល”

សម្រាប់ព័ត៌មានបន្ថែម អំពីថវិកានេះ សូមចូលមើល៖ longbeach.gov/finance


City of Long Beach
411 W. Ocean Blvd.
Long Beach, CA 90802

Visit us at www.longbeach.gov
@LongBeachCity


To request this information in an alternative format or to request a reasonable accommodation, please contact Financial Management at 562.570.6225. A minimum of three (3) business days is requested to ensure availability. Reasonable attempts will be made to accommodate request made within less than three (3) business days.